Office of the Public Advocate

**Khmer (Cambodian)**

**What happens if someone in my family can't make decisions because of disability, illness or injury?**

# តើមានអ្វីកើតឡើង ប្រសិនបើនរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ មិនអាចធ្វើការសម្រេចចិត្តដោយសារពិការភាព ជំងឺ ឬរបួស?

មនុស្សពេញវ័យមានសិទ្ធិសម្រេចចិត្តដោយខ្លួនឯង អំពីជីវិតរបស់ពួកគេ។

ប៉ុន្តែជួនកាលមនុស្សពេញវ័យមិនអាចធ្វើការសម្រេចចិត្តបានទេ ដោយសារតែពិការភាព ជំងឺ ឬរបួស។ ឧទាហរណ៍ ជំងឺវង្វេងស្មារតីធ្ងន់ធ្ងរ។

មនុស្សពេញវ័យអាចជ្រើសរើសមនុស្សម្នាក់ដើម្បីធ្វើការសម្រេចចិត្តសម្រាប់ពួកគេ ប្រសិនបើនៅពេលអនាគតពួកគេមិនអាចសម្រេចចិត្តដោយខ្លួនឯងបានទេ។

ពួកគេធ្វើបែបនេះ ដោយការបំពេញសំណុំបែបបទពិសេសមួយហៅថា 'enduring power of attorney'។

ប្រសិនបើពួកគេមិនធ្វើដូច្នេះទេ ហើយមិនអាចធ្វើការសម្រេចចិត្តដោយសារតែពិការភាព ជំងឺ ឬរបួស នោះមានសាលាក្តីមួយដែលអាចជួយបាន។ សាលាក្តីនេះហៅថា "Victorian Civil and Administrative Tribunal (VCAT)"។

VCAT អាចជ្រើសរើសនរណាម្នាក់ធ្វើការសម្រេចចិត្តអំពីប្រាក់ និងទ្រព្យសម្បត្តិរបស់បុគ្គលនោះ (ហៅថា 'administrator') (អ្នកគ្រប់គ្រង)។

VCAT អាចជ្រើសរើសនរណាម្នាក់ដើម្បីធ្វើការសម្រេចចិត្តអំពីរបៀបរស់នៅរបស់បុគ្គល (ហៅថា 'guardian') (អាណាព្យាបាល) ។

ឧទាហរណ៍ នេះអាចជាការសម្រេចចិត្តអំពីកន្លែងដែលបុគ្គលរស់នៅ ឬអំពីសេវាកម្មអ្វីខ្លះដែលពួកគេត្រូវការដូចជាជំនួយនៅផ្ទះជាដើម។

## ការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រ

ច្បាប់ចែងពីនរណាអាចសម្រេចចិត្ត អំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់មនុស្សម្នាក់ទៀត (ប្រសិនបើបុគ្គលនោះមិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន)។ ឧទាហរណ៍ នេះអាចជាប្តី ឬប្រពន្ធ ឬកូនពេញវ័យរបស់បុគ្គល។

## ប្រសិនបើអ្នកមានសំណួរណាមួយ

អ្នកអាចទូរស័ព្ទទៅ Office of the Public Advocate (ការិយាល័យអ្នកគាំទ្រសាធារណៈ) ដើម្បីជំបូន្មាន លេខ 1300 309 337 ឬចូលមើលវិបសៃថ៍ **www.publicadvocate.vic.gov.au**

Interpreter

អ្នកអាចស្នើសុំអ្នកបកប្រែភាសាតាមទូរស័ព្ទ។

2019